# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ELECTRICITE DU CAMBODGE

អគ្គិសនីកម្ពុជា

លេខ : ១៧៤១ អសក/ហ.ពកក-អ៥

## សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា**មានកិត្តិយស សូមទូលថ្វាយ និងជម្រាបជូន សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាអតិថិជនរបស់អគ្គិសនីកម្ពុជាជ្រាបថា : ដើម្បីអនុវត្តការងារជួសជុល ថែទាំ និងផ្លាស់ប្តូរបរិក្ខារប្រព័ន្ធបណ្តាញចែកចាយ អគ្គិសនីកម្ពុជានឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ភ្លើងមួយចំនួនទៅតាមពេលវេលា និងទីកន្លែងដោយមូលហេតុដូចខាងក្រោម :

១. ថ្ងៃព្រហស្បតិ៍ទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី (១)ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១២ម៉០០ នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ6A ចាប់ពីសង្កាត់ព្រែកលៀប រហូតដល់សង្កាត់ព្រែកតាសេក ខណ្ឌឫស្សីកែវ រួមទាំងតំបន់ភ្លើងលេខ ប.ត478 ស្ថិតនៅតាមបណ្តោយផ្លូវលេខ៥៦៦ ក្នុងសង្កាត់បឹងកក់១ ខណ្ឌទួលគោក និង (២)ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៤ម៉០០ នៅតំបន់ភ្លើងលេខ P554 ស្ថិតនៅភូមិទំនប់ ក្នុងសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រួមទាំងតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិជម្ពូវ័ន ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីផ្លាស់ប្តូរបរិក្ខាបណ្តាញផ្គត់ផ្គង់អគ្គិសនី ។

២. ថ្ងៃសុក្រទី២៨ ខែកុម្ភៈ ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១២ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ១ ចាប់ពីសង្កាត់វាលស្បូវ រហូតដល់សង្កាត់ព្រែកឯង ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដើម្បីតម្លើងបរិក្ខាបណ្តាញផ្គត់ផ្គង់អគ្គិសនី ។

៣. ថ្ងៃសៅរ៍ទី០១ ខែមីនា ឆ្នាំ២០១៤ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី (១)ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១២ម៉០០ នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិមិល ក្នុងសង្កាត់ដង្កោ ខណ្ឌដង្កោ តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៣ ចាប់ពីសង្កាត់ចោមចៅ រហូតដល់សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ និង (២)ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៧ម៉០០ នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិដំណាក់ធំ៣ ភូមិទ្រា៤ ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ភូមិត្រពាំងថ្លឹង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីផ្លាស់ប្តូរបរិក្ខារ និងរុះរើគន្លងខ្សែបណ្តាញបង្កលក្ខណៈដល់ការដ្ឋានពង្រីកផ្លូវវេងស្រេង ។

៤. ថ្ងៃអាទិត្យទី០២ ខែមីនា ឆ្នាំ២០១៤ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី (១)ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៤ម៉០០ នៅតំបន់ភ្លើងលេខ ប.ត637 ស្ថិតនៅតាមបណ្តោយផ្លូវលេខ៣៧០ ក្នុងសង្កាត់បឹងកក់១ ខណ្ឌទួលគោក និង (២)ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៧ម៉០០ នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិដំណាក់ធំ៣ ភូមិទ្រា៤ ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ភូមិត្រពាំងថ្លឹង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីតម្លើងបរិក្ខារ និងរុះរើគន្លងខ្សែបណ្តាញបង្កលក្ខណៈដល់ការដ្ឋានពង្រីកផ្លូវវេងស្រេង ។

អាស្រ័យហេតុនេះ សូមសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជ្រាបជាព័ត៌មាន និងសូមអធ្យាស្រ័យចំពោះការដាច់ចរន្តអគ្គិសនីនេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ_រតនៈ**